រូបថត៖ Steve Warburton

*Angelica, កើតនៅឆ្នាំ១៩៣៩*

ដោយសារឈ្មោះ Angelica ធ្លាប់មានមកហើយ គឺចាប់តាំងពីខ្ញុំបានចេញមុខក្នុងសង្គមបានបន្តិច ពេលនោះហើយទើបខ្ញុំដឹងថា អ្នកគួរតែមានឈ្មោះអ្វីមួយ។ ដូច្នេះ ខ្ញុំក៏បានចាប់ផ្តើមប្រើឈ្មោះ និងត្រកូលជាលើកដំបូង។ ប៉ុន្តែខ្ញុំបានដឹងថា ខ្ញុំជាមនុស្សភេទទីបី ចាប់តាំងពីខ្ញុំមានអាយុប្រមាណជា ១០ឆ្នាំមកម្ល៉េះ។ វាពិតជាគួរឲ្យចម្លែកណាស់ ខ្ញុំជឿថា ពេលនោះខ្ញុំពិតជាឆ្កួតហើយ ខណៈពេលដែលពិភពលោកមានលក្ខណៈធម្មតា។ ហើយខ្ញុំបានដឹងភ្លាមថា អ្នកមិនគួរមានសភាពបែបនេះទេ ហើយវាជារឿងគួរឲ្យអាម៉ាស់ណាស់ ដូច្នេះអ្នកមិនអាចប្រាប់អ្នកណាម្នាក់ឲ្យដឹងទេ។ ជាការពិតណាស់ នៅពេលនោះ វាពិតជាពិបាកណាស់ ហើយវានៅតែពិបាកដដែលហ្នឹង។ នៅពេលដែលមិនមានប្រភពចំណេះដឹងផ្សេងៗនោះ ខ្ញុំមិនអាចរកពាក្យមកបរិយាយពីអារម្មណ៍របស់ខ្ញុំបានទេ។ ហើយទោះបីជាខ្ញុំមានពាក្យសម្រាប់បរិយាយក៏ដោយក៏ខ្ញុំនឹងមិនអាចរកឃើញពាក្យនោះនៅក្នុងវចនានុក្រមដែរ។ ម៉្យាងទៀត អ៊ីនធើណិតក៏គ្មានហើយក៏មិនដឹងថាត្រូវនិយាយជាមួយនឹងអ្នកណាដែរ។

ក្រោយមក ខ្ញុំបានជួបប្រពន្ធរបស់ខ្ញុំ។ យើងបានជួបគ្នាដូចជាលឿនដែរ គឺតាំងពីពេលដែលនាងមានអាយុ ១៣ឆ្នាំម្ល៉េះ ហើយខ្ញុំមានអាយុ ១៥ឆ្នាំ ហើយនៅពេលដែលខ្ញុំមានអាយុ ១៦ឆ្នាំខ្ញុំបានប្រាប់នាងអំពីរឿងនេះ។ ដរាបណានាងនៅមានជីវិត រឿងនេះនៅតែជាអាថ៌កំបាំងរវាងយើងទាំងពីរនាក់។ វាដូចជាមិនគួរឲ្យជឿទេដែលត្រូវ... យើងទាំងពីរបានព្រមព្រៀងថាដោយសារមូលហេតុសង្គម យើងមិនអាចលាតត្រដាងរឿងណាមួយបានទេ។ ប៉ុន្តែនៅពេលនាងទទួលមរណភាព ខ្ញុំក៏បានដឹងថា ខ្ញុំមិនអាចដោះស្រាយរឿងនេះដោយខ្លួនឯងបានទេ។ ខ្ញុំរស់នៅ Gothenburg ប៉ុន្តែខ្ញុំបានទៅប្រទេសអង់គ្លេស ដើម្បីចេញមុខក្នុងសង្គម។ អ្នកមានគំនិតដ៏ចម្លែកបែបនេះតាំងពីដំបូងម្ល៉េះ។ អ្នកជឿថា អ្នកគឺជាចំណុចកណ្តាលនៃការចាប់អារម្មណ៍របស់អ្នកគ្រប់គ្នា ហើយថាអ្នកនឹងបង្កឲ្យមានរឿងអាស្រូវកើតឡើង។ ប៉ុន្តែ ការពិតដ៏ជូរចត់នោះគឺថា មនុស្សទាំងឡាយមិនខ្វល់ខ្វាយអំពីអ្នកដទៃប៉ុន្មានទេ ដូច្នេះ តាមពិតទៅ ក៏មិនមានអ្វីច្រើន

ត្រូវព្រួយបារម្ភដែរ។ ប៉ុន្តែ អ្នកមិនបានដឹងពីរឿងនេះទេ ទាល់តែពេលក្រោយមកទៀតទើបអ្នកបានដឹង។

នេះហើយគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀតដែលមនុស្សជាច្រើន ចូលដល់វ័យចំណាស់ខ្លាំងទៅហើយ ទើបហ៊ានចេញមុខក្នុងសង្គម ពោលគឺនៅក្នុងជំនាន់ខ្ញុំតែម្តង ហើយអ្នកទាំងនោះក្មេងជាងគ្នាបន្តិចបន្តួចប៉ុណ្ណោះ។ ជារឿងធម្មតាទៅហើយដែលអ្នកចំណាយពេលពាក់កណ្តាលជីវិតដើម្បីគិតពីវា មុនពេលហ៊ានចេញមុខក្នុងសង្គម។ ទោះយ៉ាងណាក៏ដោយនេះមិនមែនជាអ្វីដែលអ្នកធ្វើដើម្បីបង្កហេតុនោះទេ ប៉ុន្តែក៏ព្រោះតែអ្នកចាំបាច់ត្រូវតែធ្វើវា។ ប្រសិនបើអ្នកមិនអាចក្លាយជាមនុស្សដែលជាធាតុពិតរបស់អ្នកទេ អ្នកនឹងមានទុក្ខសោកខ្លាំងបំផុត – នេះគឺជាការពិតដែលគេធ្លាប់បានដឹងឮជាច្រើនមកហើយ។

អ្នកដែលបានរកឃើញពីវិធីបរិយាយដ៏ល្អបំផុតអំពីជីវិតនោះគឺ Søren Kierkegaard គាត់បានសង្ខេបអត្ថន័យវាត្រឹមមួយប្រយោគប៉ុណ្ណោះគឺៈ ទាល់តែងាកមើលក្រោយ ទើបយល់ពីជីវិត ប៉ុន្តែជីវិតរបស់យើងត្រូវតែសំឡឹងឆ្ពោះទៅមុខ។